# សុន្ទរកថា
# ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី
# រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
# ក្នុងពិធីប្រកាសដាក់ឱ្យអនុវត្ត
# "យុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ២០២១-២០២៣ របស់
# ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ"
# សណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា
# ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១

***ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា អង្គពិធីទាំងមូលជាទីមេត្រី!***

ថ្ងៃនេះ ខ្ញុំមានក្តីសោមនស្សរីករាយ ដែលបានចូលរួមក្នុងពិធីប្រកាសដាក់ឱ្យអនុវត្ត "**យុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ២០២១-២០២៣**" របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ ក្នុងឱកាសនេះ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាតំណាងក្រសួងស្ថាប័ននិងតំណាងសភាពាណិជ្ជកម្មដែលបានចំណាយពេលវេលាដ៏មានតម្លៃអញ្ជើញចូលរួមនៅក្នុងកម្មវិធីនេះ។

ជាមួយគ្នានេះ ខ្ញុំក៏សូមកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ និងក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ចរបស់ក្រសួង ដែលបានខិតខំបំពេញការងារនេះ រហូតដល់សម្រេចបានលទ្ធផលនៅថ្ងៃនេះ។

ទន្ទឹមនេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះក្រសួងស្ថាប័នដែលបានជួយគាំទ្រ និងផ្តល់ធាតុចូលដ៏មានសារៈសំខាន់ក្នុងឯកសារយុទ្ធសាស្ត្រនេះ។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី**

គំនិតស្តីពីការបញ្ចូលការងារសេដ្ឋកិច្ចឲ្យទៅជាសមាសភាគដ៏សំខាន់ និងខានមិនបាននៃការងារការទូតរបស់យើងមានតាំងពីឆ្នាំដំបូងនៃការចូលមកកាន់តំណែងជារដ្ឋមន្ត្រីការបរទេសនិងសហប្រតិបត្តិការអន្តរជាតិរបស់ខ្ញុំមកម្ល៉េះ។ បន្ទាប់ពីបានប្រមូលធាតុចូល និងធាតុផ្សំល្អមគ្រប់គ្រាន់ស្តីពីសមាសភាគថ្មីមួយនេះហើយនោះ ក្រសួងក៏បានប្រកាសជាផ្លូវការជាលើកដំបូង ចាត់ទុកការងារការទូតសេដ្ឋកិច្ចជាការងារធំមួយក្នុងចំណោមការងារធំទាំង៥របស់ក្រសួងនៅពេលប្រារព្ធសន្និបាតប្រចាំឆ្នាំរបស់ក្រសួងនាដើមឆ្នាំ២០១៨។ គោលនយោបាយនេះត្រូវបាន **សម្តេចតេជោនាយករដ្ឋមន្ត្រី** គាំទ្រយ៉ាងពេញលេញ ដោយសម្តេច បានបញ្ជាក់ថា ការទូតសេដ្ឋកិច្ចគឺជាអាទិភាពមួយសម្រាប់គោលនយោបាយការបរទេសកម្ពុជា ដោយមានតួនាទីយ៉ាងសំខាន់ក្នុងការធ្វើពិពិធកម្មប្រភពកំណើននិងដៃគូសេដ្ឋកិច្ច និងពាណិជ្ជកម្ម។ ផ្អែកលើស្មារតីនេះ យើងបានចំណាយពេលជាង ២ ឆ្នាំ ដើម្បីសម្រេចតាក់តែងឯកសារយុទ្ធសាស្ត្រដែលយកមកផ្សព្វផ្សាយថ្ងៃនេះ។

ឯកសារយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឆ្នាំ២០២១-២០២៣ ត្រូវបានរៀបចំឡើងនៅក្នុងកាលៈទេសៈដែលស្ថានភាពពិភពលោក ក៏ដូចជាកម្ពុជាកំពុងប្រឈមទៅនឹងការគំរាមកំហែងធ្ងន់ធ្ងរបំផុតមិនធ្លាប់ជួប ក្នុងរយៈពេលជាង៣ទសវត្សចុងក្រោយនេះ។ ការគំរាមគំហែងនេះបណ្តាលមកពីកត្តាគួបផ្សំគ្នាជាច្រើន។ កត្តាធំជាងគេ២គឺ ទី១កត្តាធម្មជាតិ និងទី២កត្តាមនុស្ស។

ការផ្ទុះនិងការរីករាលដាលនៃជំងឺឆ្លងកូវីដ-១៩ បានធ្វើឱ្យពិភពលោកទាំងមូលរង្គោះរង្គើ។ កត្តាធម្មជាតិមួយនេះ មិនត្រឹមតែប៉ះពាល់ដល់វិស័យសុខាភិបាល ក្នុងកំរិតមិនធ្លាប់មានប៉ុណ្ណោះទេ វាក៏បណ្ដាលឱ្យសេដ្ឋកិច្ចពិភពលោកទាំងមូលធ្លាក់ក្នុងវិបត្តិជ្រាលជ្រៅ។ កូវីដ-១៩ បានរុញឱ្យប្រវាក់ផ្គត់ផ្គង់តំបន់ និងពិភពលោករអាក់រអួល និងកាត់ផ្ដាច់ក្នុងកំរិតធ្ងន់ធ្ងរ វិស័យទេសចរណ៍ធ្លាក់ចុះយ៉ាងគំហុកសឹងដល់បាត វិស័យដឹកជញ្ជូន ពិសេសផ្លូវអាកាសគាំងដំណើរការ ទំនុកចិត្តខាងធុរកិច្ច និងអតិថិជនចុះខ្សោយ ដោយសារវិធានការរឹតត្បិតនានា ដើម្បីឃុំគ្រងកុំឱ្យជំងឺរាលដាល។ ជំងឺឆ្លងនេះ ក៏បង្កហានិភ័យកាន់តែធំឡើង នៃការក្ស័យធនផ្នែកធុរកិច្ច ដែលនឹងបង្កការបាត់បង់ការងាររបស់មនុស្សរាប់រយលាននាក់។ ទោះបីជាមានដំណើរការចាក់វ៉ាក់សាំងបង្ការជំងឺនេះជាបណ្ដើរៗហើយក៏ដោយ ក៏គេពុំទាន់អាចប្រមើលមើលឃើញអំពីការវិលត្រឡប់មកវិញ នូវប្រក្រតីភាពនៃដំណើរការសេដ្ឋកិច្ចពិភពលោកនោះដែរ។

ផលប៉ះពាល់របស់កូវីដ-១៩ មិនត្រឹមតែលាតសន្ធឹងលើវិស័យសេដ្ឋកិច្ចសង្គម និងហិរញ្ញវត្ថុប៉ុណ្ណោះទេ តែក៏ហក់ចូលក្នុងសង្វៀននយោបាយ ដោយការធ្វើនយោបាយតូបនីយកម្ម ដើម្បីយកកំហុសនៃអសមត្ថភាពរបស់ខ្លួនក្នុងការទប់ស្កាត់ជំងឺនេះ ទៅទំលាក់ឱ្យអ្នកដទៃ។ ការប្រកួតប្រជែងគ្នាខាងភូមិសាស្ត្រនយោបាយ និងយុទ្ធសាស្ត្រដ៏តានតឹងរវាងមហាអំណាចធំបំផុតទាំងពីរ កំពុងឈានទៅរកសង្គ្រាមត្រជាក់បែបថ្មី ដែលធ្វើឱ្យមានការផ្លាស់ប្ដូរយ៉ាងជ្រាលជ្រៅ ឆាប់រហ័ស ពិបាកប៉ាន់ស្មាន និងប្រកបដោយគ្រោះថ្នាក់បំផុត។ កត្តាមនុស្សនេះ កំពុងធ្វើឱ្យស្ថិរភាព និងវិបុលភាព រយៈពេលជាង៧០ឆ្នាំដែលកើតចេញពីសណ្ដាប់ធ្នាប់អន្តរជាតិផ្អែកលើពហុប៉ូលនិយម

និងច្បាប់អន្តរជាតិនោះ ទទួលរងភាពរង្គោះរង្គើយ៉ាងខ្លាំង។ នេះក៏ដោយសារការរំលោភបំពាន និងលែងគោរពនូវគុណតម្លៃទាំងឡាយ ដែលជាមូលដ្ឋានគ្រឹះនៃសណ្តាប់ធ្នាប់នេះ និងការងាកទៅរកឯកតោភាគីនិយម ការប្រើកំលាំងបាយគាបសង្កត់ប្រទេសទន់ខ្សោយ។

ការប្រជែងគ្នារវាងមហាអំណាចអាមេរិក និងចិន ដែលនាដើមអាណត្តិរបស់ប្រធានាធិបតី Trump បានចាប់ផ្តើមពីការបង្កសង្គ្រាមពាណិជ្ជកម្មនោះ បានរីករាលដាលដល់សមរភូមិផ្សេងទៀតមាន សេដ្ឋកិច្ច វិទ្យាសាស្ត្រ បច្ចេកវិទ្យា យោធា ចារកម្ម ល្បែងទំលាក់កំហុស និងបញ្ហាសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ និងមនោគមវិជ្ជា។ ទោះបីជាមានការព្យាករណ៍ថា ប្រធានាធិបតីជាប់ឆ្នោតថ្មីរបស់អាមេរិក (លោក ចូ បៃដិន) អាចផ្លាស់ប្តូរទិសដៅគោលនយោបាយការបរទេស ពី «អាមេរិកជាចម្បង» មកផ្តោតលើ «ប្រព័ន្ធពហុភាគីនិយម» វិញក៏ដោយ ក៏ពុំមានសញ្ញាណណាមួយបង្ហាញថា ការប្រជែងឥទ្ធិពល និងអំណាចនេះបានថមថយចុះនោះទេ។ ផ្ទុយទៅវិញ វាអាចបន្ថែមនូវថាមវន្តកាន់តែខ្លាំង និងបង្កនូវការលំបាក ការប្រឈម និងកង្វល់ស្មុគស្មាញដល់ប្រទេសតូចៗ ដូចកម្ពុជា ទាំងនយោបាយ ទាំងសេដ្ឋកិច្ចផង។

អ្វីដែលធ្ងន់ធ្ងរនោះ គឺការរួមបញ្ចូលគ្នានៃកត្តាទាំងពីរក្នុងពេលតែមួយ ពោលគឺរដ្ឋាភិបាល ត្រូវចាត់វិធានការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដផង និងដោះស្រាយបញ្ហាប្រឈមខាងសេដ្ឋកិច្ច និងសង្គម ដែលបណ្តាលមកពីការរាតត្បាតនៃជំងឺនេះផង។ ហើយធ្ងន់ធ្ងរបំផុតទៅទៀតសំរាប់កម្ពុជា គឺថែមពីលើអម្រែកទាំងសងខាងស្មារបស់យើង គឺការដករបបអនុគ្រោះពន្ធក្រោមប្រព័ន្ធ EBA 20%។

"ទណ្ឌកម្ម" ដែល EU បានសម្រេចដាក់មកលើកម្ពុជា ក្នុងគ្រាដែលប្រទេសតូចរបស់យើងកំពុងប្រមូលកិច្ចប្រឹងប្រែងគ្រប់យ៉ាង ធនធានគ្រប់ប្រភេទ និងមធ្យោបាយចំរុះ ដើម្បីទប់ទល់នឹងការរាលដាលនៃជំងឺកូវីដ-១៩ ផង និងទប់កុំឱ្យសេដ្ឋកិច្ចដួលរលំផង ត្រូវបាន **សម្តេចតេជោនាយករដ្ឋមន្រ្តី** ហៅយ៉ាងច្បាស់ក្នុងសុន្ទរកថាទៅកាន់មហាសន្និបាត អ.ស.ប. លើកទី៧៥ ថាជា "ភាពអយុត្តិធម៌"។

**សម្តេច** បានថ្លែងថានាឱកាសនោះថា៖ «រឿងអយុត្តធម៌នេះ រំលឹកខ្ញុំអំពី "**ស្លាកស្នាម**" ប្រវត្តិសាស្រ្ត។ ប្រមាណជាង៤០ឆ្នាំមុន កម្ពុជាត្រូវបានរំដោះចេញពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម ដែលប្រជាជនកម្ពុជា ជាង **២លាននាក់** បានបាត់បង់ជីវិតនៅក្នុងរបបដ៏ព្រៃផ្សៃនេះ។ អ្នករស់រានមានជីវិតទាំងបាក់ស្មារតី និងសល់តែបាតដៃទទេ គឺជាអ្នកដែលស្តារប្រទេសជាតិពីគំនរផេះផង់។ អ្វីដែលគួរឱ្យហួសចិត្ត គឺអ្នកដែលរស់រានមានជីវិតទាំងនោះបែរជាទទួលរងទណ្ឌកម្មពីសមាជិកភាគច្រើន នៃអង្គការសហប្រជាជាតិដែលថែមទាំងបានអនុញ្ញាតឱ្យមេពិឃាតខ្មែរក្រហម កាន់អាសនៈរបស់កម្ពុជានៅអង្គការសហប្រជាជាតិទៅវិញ។ រដ្ឋាភិបាលទាំងនោះ ដែលបានផ្សព្វផ្សាយឥតឈប់ឈរអំពីលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស គឺជាអ្នកដែលបានរារាំងប្រជាជនយើងពីការទទួលបាននូវសិទ្ធិមូលដ្ឋានបំផុតរបស់មនុស្ស គឺ ចំណីអាហារ សុខុមាលភាព ការអប់រំ ផ្ទះសម្បែង ការអភិវឌ្ឍ និងជាពិសេសសុខសន្តិភាព អស់រយៈពេលជាង១២ឆ្នាំ។

ការណ៍ដែលសហភាពអឺរ៉ុបដកហូត EBA មួយផ្នែកពីកម្ពុជា នៅពេលដែលប្រទេសនេះកំពុងប្រឹងប្រែងតស៊ូជម្នះជំងឺរាតត្បាតកូវីដ-១៩ គឺជារឿងច្រំដែលនៃប្រវត្តិសាស្រ្ត។ ទោះបីយ៉ាងណាក៏ដោយក៏កម្ពុជានៅតែប្តេជ្ញា

ចិត្តយ៉ាងពេញទំហឹង ដូចដែលខ្លួនធ្លាប់បានធ្វើអស់រយៈពេល៤០ឆ្នាំកន្លងមកនេះ ក្នុងការការពារនូវអ្វីដែលខ្លួនជឿជាក់ថាជាមាគ៌ាដ៏ត្រឹមត្រូវ នោះគឺការពារអធិបតេយ្យជាតិ និងថែរក្សាសន្តិភាព ដែលកសាងបានយ៉ាងលំបាកលំបិន និងទទួលបានការសាទរពេញទំហឹងដោយប្រជាជាតិកម្ពុជាទាំងមូល ដែលបានឆ្លងកាត់សោកនាដកម្មដ៏ខ្លោចផ្សាបំផុត និងកំពុងតែងើបឈរឡើងជាប្រជាជាតិមួយ ស្មើមុខមាត់ ស្មើភាព និងស្មើសិទ្ធិ ជាមួយបណ្តាប្រទេសនៅក្នុងតំបន់ និងសកលោក។»

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី**

ក្នុងរយៈពេលជាង២០ឆ្នាំចុងក្រោយនេះ ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងប៉ិនប្រសប់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ប្រទេសយើងសម្រេចបាននូវសន្តិភាព ស្ថិរភាពនយោបាយ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ជាមួយនឹងកំណើនជាមធ្យមជាង៧% ក្នុងមួយឆ្នាំ និងបានប្រែក្លាយខ្លួនពីប្រទេសមានចំណូលកម្រិតទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ២០១៥ ព្រមទាំងត្រូវបានសហគមន៍អន្តរជាតិប្រសិទ្ធនាមនៅឆ្នាំ២០១៦ ថាជា «**ខ្លាសេដ្ឋកិច្ចថ្មីនៅអាស៊ី**»។ ជាមួយសមិទ្ធផលទាំងនេះ រាជរដ្ឋាភិបាលបានកំណត់ចក្ខុវិស័យមួយច្បាស់លាស់ ដើម្បីប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅក្នុងឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។ ប៉ុន្តែផលអាក្រក់នៃកូវីដ-១៩ បានទុចដំណើរការរីកចំរើននៃសេដ្ឋកិច្ចជាតិយើង និងធ្វើឱ្យប៉ះពាល់យ៉ាង

ធ្ងន់ធ្ងរដល់វិស័យជាច្រើន ក្នុងនោះប៉ះពាល់ខ្លាំងជាងគេគឺ ឧស្សាហកម្មទេសចរណ៍ ដឹកជញ្ជូន និងអចលនទ្រព្យ។

នៅចំពោះមុខសភាពការណ៍បែបនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការបន្ទាន់ ហ្មត់ចត់ ស៊ីជម្រៅ និងមានប្រសិទ្ធភាព ដើម្បីគាំទ្រវិស័យសេដ្ឋកិច្ច-សង្គម សំដៅជួយរក្សាលំនឹងផលិតកម្ម អាជីវកម្ម និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលទទួលរងគ្រោះ។

បន្ថែមពីលើនេះ រាជរដ្ឋាភិបាលក៏បានដាក់ចេញជាបន្តបន្ទាប់នូវវិធានការកែទម្រង់មុតស្រួចនានា ដូចជា ការកែលម្អច្បាប់វិនិយោគ និងប្រព័ន្ធលើកទឹកចិត្ត ដើម្បីជួយសម្របសម្រួល បង្កបរិយាកាសកាន់តែល្អ និងទាក់ទាញធុរជន និងវិនិយោគិននានាបន្ថែមទៀត។ វិធានការបន្ថែម ដើម្បីបន្តគ្រប់គ្រងផលប៉ះពាល់របស់ជំងឺកូវីដ-១៩ លើវិស័យសេដ្ឋកិច្ច-សង្គមសំខាន់ៗ និងដើម្បីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជានោះ បានឈានដល់ជុំទី៧រួចទៅហើយ។ វិធានការទាំងនោះសំដៅជួយទ្រទ្រង់វិស័យសុខាភិបាល ឧស្សាហកម្មកាត់ដេរនិងស្បែកជើង ទេសចរណ៍ អាកាសចរណ៍ស៊ីវិល SMEs ជួយទំនុកបំរុងពលករ គាំពារសង្គម គាំទ្រកំណើន បន្ធូរបន្ថយបន្ទុកពន្ធ។ល។

រាជរដ្ឋាភិបាលក៏កំពុងរៀបចំច្បាប់ស្តីពី PPP គំរោងជានាឥណទានរបស់រដ្ឋ ការចុះបញ្ជីតាមប្រព័ន្ធOnline គំនិតផ្តួចផ្តើមរៀបចំសេដ្ឋកិច្ចឌីជីថល។ល។ ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-ចិន និងកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP) ក៏ដូចជាដំណើរឆ្ពោះទៅមុខនៃការចរចាកិច្ចព្រមព្រៀងដូចគ្នាជាមួយសាធារណរដ្ឋកូរ៉េ គឺ

ជាសមិទ្ធិផលថ្មីរបស់រាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយផលប៉ះពាល់នានាផង និងជំរុញការស្តារ និងពង្រឹងសេដ្ឋកិច្ចឡើងវិញក្រោយ Covid-19 ផង។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី**

ស្ថានការណ៍ដូចបានរៀបរាប់ខាងលើនេះ កាន់តែបញ្ជាក់ឱ្យយើងឃើញច្បាស់ពីភាពត្រឹមត្រូវ និងចាំបាច់បំផុត ក្នុងការផ្លាស់ប្តូររបៀបរបបការងារ ពីការធ្វើការទូតប្រពៃណី មកជាការទូតដែលផ្តោតសំខាន់ដល់ការលើកស្ទួយសេដ្ឋកិច្ច វប្បធម៌ និងទេសចរណ៍ ពោលគឺការអនុវត្តគោលនយោបាយការបរទេសមួយដែលយកវិបុលភាពសេដ្ឋកិច្ចធ្វើជាស្នូល។ គ្មានប្រទេសណាដែលបានទទួលជោគជ័យ ដោយមិនយកបញ្ហាសេដ្ឋកិច្ចធ្វើជារបៀបវារៈសំខាន់របស់ខ្លួនឡើយ។

ដោយទទួលស្គាល់ពីសារៈសំខាន់នៃការរួមចំណែករបស់វិស័យការបរទេសទៅលើការអភិវឌ្ឍសេដ្ឋកិច្ច រយៈពេលជាង២ឆ្នាំនេះ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានខិតខំជំរុញការងារការទូតសេដ្ឋកិច្ច តាមរយៈការពង្រឹងសមត្ថភាពធនធានមនុស្ស ការបណ្តុះបណ្តាលអ្នកការទូតឱ្យមានវិជ្ជាជីវៈ ការរៀបចំប្រមូល និងចងក្រងផ្ទាំងព័ត៌មានអំពីសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ និងទេសចរណ៍ សម្រាប់អ្នកការទូតយើងប្រើប្រាស់ និងជួបប្រាស្រ័យជាមួយភ្ញៀវ ធុរជន ពលរដ្ឋ និងថ្នាក់ដឹកនាំនៃប្រទេសម្ចាស់ផ្ទះជាមិត្ត និងចូលរួមពិធីតាំងពិព័រណ៍ ពាណិជ្ជ-កម្ម វប្បធម៌ ការធ្វើបទបង្ហាញទាក់ទាញវិនិយោគ និងការជួយសម្របសម្រួលនូវដំណើរ និងសំណើរបស់ធុរជន និងក្រុមហ៊ុនបរទេសនានា។

ជាងនេះទៅទៀត ក្រសួងការបរទេសបានប្ដេជ្ញារៀបចំតាក់តែងនូវយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចនេះ ដើម្បីជាត្រីវិស័យក្នុងការពង្រឹងប្រសិទ្ធភាពការងារផ្នែកការទូតសេដ្ឋកិច្ច និងដើម្បីចូលរួមជាវិភាគទានពង្រឹងជន្ទល់កំណើនសេដ្ឋកិច្ច កាត់បន្ថយការពឹងផ្អែកលើជំនួយពីខាងក្រៅ និងលើកកម្ពស់ផលប្រយោជន៍កម្ពុជានៅក្នុងតំបន់ និងអន្តរជាតិ ដោយផ្ដោតទៅគោលដៅ ០៤ធំៗ រួមមាន៖ ១) **ការជំរុញពាណិជ្ជកម្មអន្តរជាតិ, ២) ការទាក់ទាញ ការវិនិយោគទុនផ្ទាល់ពីបរទេស ៣) ការលើកកម្ពស់វិស័យទេសចរណ៍ និង ៤) ការជំរុញការផ្លាស់ប្តូរវប្បធម៌ (រួមទាំងការផ្សព្វផ្សាយពីមុខម្ហូបខ្មែរផងដែរ)។**

តាមរយៈយុទ្ធសាស្ត្រខាងលើ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនឹងដើរតួនាទី៖ (**ទី១**). ជាអ្នកសម្របសម្រួល និងជំរុញយន្តការដែលមានស្រាប់ ដើម្បីទាក់ទាញការវិនិយោគទុនផ្ទាល់ពីបរទេស ជំរុញឱ្យមានកំណើននៃការធ្វើពាណិជ្ជកម្មទ្វេភាគី និងពហុភាគី និងទាក់ទាញភ្ញៀវទេសចរណ៍តាមរយៈការពង្រឹងតម្លៃវប្បធម៌ខ្មែរនៅក្រៅប្រទេស, និង(**ទី២**). អភិវឌ្ឍធនធានអ្នកការទូតជំនាន់ថ្មីប្រកបដោយវិជ្ជាជីវៈ សមត្ថភាពខ្ពស់សកម្មការពារ និងលើកស្ទួយផលប្រយោជន៍ជាតិលើគ្រប់វិស័យ។

នៅក្នុងន័យនេះ អនុញ្ញាតឱ្យខ្ញុំគូសបញ្ជាក់បន្ថែមជូន ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាតំណាងក្រសួងស្ថាប័នពាក់ព័ន្ធថា នៅក្នុងការរៀបចំអនុវត្តយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចនេះ ក្រសួងការបរទេសពុំមានភារកិច្ចដើរតួនាទីជំនួសឱ្យក្រសួងស្ថាប័នជំនាញ ដែលកំពុងអនុវត្តការងារនេះស្រាប់នោះទេ។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី**

ដើម្បីធានាអនុវត្តសម្រេចដោយជោគជ័យនូវយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចនេះ ទាមទារឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ដូចជា ស្ថានតំណាងកម្ពុជាប្រចាំនៅបរទេស ក្រសួងស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាលកម្ពុជា និងវិស័យឯកជនផងដែរ។ ដូចនេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ក្រសួងស្ថាប័នជំនាញ និងភាគីពាក់ព័ន្ធនានា នឹងបង្កើនការគាំទ្រដល់ការអនុវត្តឯកសារយុទ្ធសាស្ត្រនេះ ពោលគឺការជំរុញ និងពង្រីកផលប្រយោជន៍សេដ្ឋកិច្ចជាតិ។

ជាថ្មីម្តងទៀត ខ្ញុំសូមឆ្លៀតក្នុងឱកាសនេះសម្តែងនូវការកោតសរសើរដោយស្មោះជូនចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរបស់ក្រសួងគ្រប់លំដាប់ថ្នាក់ ជាពិសេសក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច ដែលបានខិតខំប្រឹងប្រែង និងរួមចំណែកយ៉ាងសកម្មក្នុងការរៀបចំយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចនេះ ព្រមទាំងបានរៀបចំចងក្រងសៀវភៅមុខម្ហូបខ្មែរ ដែលមានឈ្មោះថា «The Taste of ANGKOR» ឱ្យចេញជារូបរាងឡើង។ ទន្ទឹមនឹងនេះ ខ្ញុំសូមសម្តែងនូវអំណាអរគុណដ៏ស្មោះចំពោះក្រសួង និងស្ថាប័នជំនាញ ដែលបានផ្តល់កិច្ចសហការនិងគាំទ្រដល់ការរៀបចំកម្មវិធី ក៏ដូចជាការរៀបចំយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចនេះ។

ជាទីបញ្ចប់ ខ្ញុំសូមប្រកាសដាក់ឱ្យអនុវត្ត «យុទ្ធសាស្រ្តការទូតសេដ្ឋកិច្ចឆ្នាំ២០២១-២០២៣» និងដាក់ឱ្យប្រើប្រាស់សៀវភៅមុខម្ហូបខ្មែរដែលមានឈ្មោះថា « The Taste of ANGKOR » ចាប់ពីពេលនេះតទៅ និងសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា សូមប្រកបដោយពុទ្ធពរទាំង៤ប្រការគឺ៖ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ!